# ព្រះរាជក្រឹត្យ

នស/រកត/០២០៥/០៧០

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩, ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៩ និងព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧០ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំងសមាជិក សមាជិកាព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០២០៤/០៣០ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៤ ស្ដីពីការបន្តនីតិកាលទី១ នៃព្រឹទ្ធសភា ដែលត្រូវផុតកំណត់នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤ ក្នុងរយៈពេលមួយឆ្នាំទៅមុខទៀត
- បានទ្រង់យល់ព្រះរាជសារ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៥ ដែលប្រោសព្រះរាជទានការយល់ព្រមលើយោបល់របស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា អំពីការបន្តនីតិកាលទី១ របស់ព្រឹទ្ធសភាមួយឆ្នាំទៅមុខទៀត និងព្រះរាជតិះអោយចាត់ការបន្តតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១០២ ថ្មីនៃរដ្ឋធម្មនុញ្ញ
- តាមសេចក្ដីក្រាបបង្គំទូលស្នើរបស់ប្រធានព្រឹទ្ធសភា តាមលិខិតលេខ ០២៧/០២០៥/ពស/នវ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥

### ត្រាស់បង្គាប់

**មាត្រា១:** ប្រកាសបន្តនីតិកាលទី១ នៃព្រឹទ្ធសភា ដែលត្រូវផុតកំណត់នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥ ក្នុងរយៈពេលមួយឆ្នាំទៅមុខទៀត ។

**មាត្រា២:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*រកត.០២០៥.០៧៣*

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥*

លេខ: ៦២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ តាន់**